**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Sep-2014, 12:14
CMS/CFO: Sann Rada

**សំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩/អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ: **សហចៅក្រមស៊ើបអង្កេត**
កាលបរិច្ឆេទ: **ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤**
ភាសា: **អង់គ្លេស [ភាសាដើម]**
ចំណាត់ថ្នាក់ឯកសារ: **សម្ងាត់**

---

# ដីកាសម្រេចលើសំណើជាបន្ទាន់របស់យឹម ទិត្យ សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ

---

**ផ្ញើជូន**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីតំណាងជនសង្ស័យ**
សូ មូស្សេន្ទី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រ៊ីនណា
វ៉េន ពៅ

Annie DELAHAIE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Mahdev MOHAN
Barnabe NEKUI
Lyma NGUYEN
Philippine SUTZ
Beini YE

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ")[1]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ដាក់នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១[2]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ដាក់នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤[3]។

**បានឃើញ** ការបើកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពានក្រមព្រហ្មទណ្ឌ **ឆ្នាំ ១៩៥៦ អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩** និង**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៤, ៥,៦, ២៩ និង៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងមាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។

**បានឃើញ**វិធាន២១, ៤៨, ៥៥, ៥៧, ៧២ និង៧៦ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង")។

**បានពិចារណាទៅលើ** *សំណើជាបន្ទាន់របស់យឹម ទិត្យសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ* ("សំណើបន្ទាន់") ដែលបានដាក់ដោយក្រុមការពារក្តីយឹម ទិត្យ ("ជនសង្ស័យ" និង "មេធាវីជនសង្ស័យ"នៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១៤[4]។

---

[1]សំណុំរឿង០០៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ សំណុំរឿង០០៤ ឯកសារD1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។

[2]សំណុំរឿង ០០៤ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១។

[3]សំណុំរឿង ០០៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។

**បានពិចារណាទៅលើ***សារណារបស់លោកយឹម ទិត្យស្តីពីការពិចារណាសាជាថ្មីទៅលើសេចក្តីសម្រេចក្នុងការអនុញ្ញាតឲ្យលោកយឹម ទិត្យ ចូលពិនិត្យមើលសំណុំរឿង* ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ ("សារណាស្តីពីការពិចារណាសាជាថ្មី")[5]។

**បានឃើញ**ករណីខ្វែងយោបល់គ្នាចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ និង ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣។

## ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet ("ស.ច.ស.អ.ប") បានចេញការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ ដោយក្នុងនោះគាត់បានជូនដំណឹង ជនសង្ស័យថា "*លោកត្រូវបានជាប់ឈ្មោះថាជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួរកំពុងបន្តដំណើរការ ដោយយោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១*"[៦]។ ជនសង្ស័យក៏ត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងគាត់ ផងដែរ។ ត្រង់ចំណុចនេះ ស.ច.ស.អ.ប បានបញ្ជាក់ថា "ការចោទប្រកាន់ទាំងនេះគឺផ្អែកលើមូលដ្ឋានទាំងអង្គហេតុ ដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា និងអង្គហេតុដែលត្រូវបានរកឃើញនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ"[៧]។ បន្ថែមពីលើនេះទៀត ស.ច.ស.អ.ប បានអនុញ្ញាតឲ្យជនសង្ស័យមាន"សិទ្ធិមានលទ្ធភាពទទួលបានឯកសារសំណុំរឿង[ការចូលពិនិត្យមើលសំណុំរឿង]"[៨]។ នៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ

---

[4]សំណុំរឿង ០០៤ ឯកសារ D186 *សំណើជាបន្ទាន់របស់យឹម ទិត្យសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ* ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១៤។

[5]សំណុំរឿង ០០៤ ឯកសារ D186/2 *សារណារបស់លោកយឹម ទិត្យស្តីពីការពិចារណាសាជាថ្មីទៅលើសេចក្តីសម្រេចក្នុងការអនុញ្ញាតឲ្យលោកយឹម ទិត្យ ចូលពិនិត្យមើលសំណុំរឿង* ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤។

[៦]សំណុំរឿង០០៤ ឯកសារD109 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ[វិធាន ២១(១)(ឃ)]* ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១។

[៧]សំណុំរឿង ០០៤ ឯកសារ D109 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ[វិធាន ២១(១)(ឃ)]* ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២ ។

[៨]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤ ។

២០១២ ដោយមិនមានវត្តមានរបស់ជនសង្ស័យ[9] ស.ច.ស.អ.ប បានប្រគល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅតាមអាសយដ្ឋានលំនៅដ្ឋានរបស់ជនសង្ស័យ[10]។

២. នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ ចៅក្រម Harmon ("ស.ច.ស.អន្តរជាតិ") បានចេញ *សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី[កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ដែលពាក់ព័ន្ធនឹងជនសង្ស័យម្នាក់ទៀតនៅក្នុងសំណុំរឿង ០០៤[11]។ សេចក្តីសម្រេចនេះ *រួមមាន*ការពិចារណាឡើងវិញ និងលុបចោលសេចក្តីសម្រេចរបស់ ស.ច.ស.អ.ប ដែលអនុញ្ញាតឲ្យជនសង្ស័យនៅក្នុងករណីនោះចូលពិនិត្យមើលសំណុំរឿង ០០៤។

៣. នៅថ្ងៃទី១២ ខែ កុម្ភៈ ឆ្នាំ ២០១៤ លោក មូ សុវណ្ណី សហមេធាវីជាតិរបស់ជនសង្ស័យ បានស្នើសុំចូល Zylab និងចូលពិនិត្យមើលឯកសារនានានៅក្នុងសំណុំរឿង[12] បន្ទាប់មកក៏មានលិខិតអ៊ីម៉េលបន្ថែមមួយទៀតនៅថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៤[13]។ ក្រឡាបញ្ជីប្រចាំការិយាល័យសហចៅក្រមស៊ើបអង្កេត("ក.ស.ច.ស")បានឆ្លើយតបថា គាត់នឹងជូនដំណឹង លោក មូ សុវណ្ណី ភ្លាមៗ នៅពេលណាដែលគាត់ទទួលបានចម្លើយតបពីសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") [14]។ នៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១៤ មេធាវីជនសង្ស័យ បានដាក់សំណើបន្ទាន់ ដោយស្នើសុំ ស.ច.ស បង្គាប់ឲ្យការិយាល័យរដ្ឋបាល អនុញ្ញាតឲ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿង ០០៤[15]។

---

[9]សំណុំរឿង ០០៤ ឯកសារ D111 *លិខិតជូនទៅអង្គភាពគាំពារការពារក្តី ស្តីពីការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)]* ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៣។

[10]នៅក្នុងលិខិតដែល ស.ច.ស.អ.ប បានផ្ញើទៅអង្គភាពគាំពារការពារក្តី នៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ កាលបរិច្ឆេទនៃការជូនដំណឹងផ្ទាល់មាត់ គឺចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២។ ទោះបីយ៉ាងណា ដោយយល់ឃើញថា លិខិតនេះចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ ហើយការជូនដំណឹងដូចគ្នានេះទៅជនសង្ស័យផ្សេងទៀតបានធ្វើឡើងនៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ស.ច.ស.អន្តរជាតិ យល់ឃើញថា ការចុះកាលបរិច្ឆេទថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ គឺមានការភាន់ច្រឡំ ហើយនឹងពិចារណាថាការជូនដំណឹងនោះត្រូវបានធ្វើឡើងនៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២។

[11]សំណុំរឿង ០០៤ ឯកសារ D121/4 *សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី [កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣។

[12]អ៊ីម៉េលពីលោកស្រូ មូសុវណ្ណី ជូនលោក លី ច័ន្ទតុលា "ដាក់ពាក្យសុំចូល zylab" ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៤។

[13]អ៊ីម៉េលពីលោកស្រូ មូសុវណ្ណី ជូនលោក លី ច័ន្ទតុលា "តាមដានសំណើសុំចូល zylab" ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៤។

[14]អ៊ីម៉េលពីលោកលី ច័ន្ទតុលា ជូន លោកស្រូ មូសុវណ្ណី "យោង៖ បន្តសំណើសុំចូល zylab" ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៤។

[15]សំណើបន្ទាន់។

៤. នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ នៅក្នុង*ដីកាសម្រេចទាក់ទងនឹងសំណើជាបន្ទាន់របស់យឹម ទិត្យ សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ* ("ដីកាសម្រេចបឋម")[16] ស.ច.ស.អន្តរជាតិ បានជូនដំណឹងជនសង្ស័យអំពីបំណងរបស់គាត់ក្នុងការពិចារណាឡើងវិញទៅលើការជូនដំណឹងមុនៗរបស់ចៅក្រម Kasper-Ansermet អំពីសិទ្ធិរបស់ជនសង្ស័យ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ និងថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ("ការជូនដំណឹង")[17] ហើយបានអញ្ជើញជនសង្ស័យ និងភាគីនានាឲ្យដាក់សេចក្តីសន្និដ្ឋានដែលខ្លួនអាចមានអំពីបញ្ហានេះ[18]។

៥. នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ មេធាវីជនសង្ស័យ បានដាក់ *សំណើជាបន្ទាន់របស់យឹម ទិត្យ សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី*[19] ដោយស្នើសុំការអនុញ្ញាតបណ្តោះអាសន្នចូលពិនិត្យមើលសំណុំរឿង ខណៈដែលរង់ចាំ ស.ច.ស.អន្តរជាតិ ធ្វើការពិចារណាឡើងវិញទៅលើការជូនដំណឹង ដោយសំណើនេះផ្អែកលើមូលដ្ឋានថា ជនសង្ស័យទទួលបានរួចហើយនូវការអនុញ្ញាតតាមផ្លូវច្បាប់ឲ្យចូលពិនិត្យមើលសំណុំរឿង ពី ស.ច.ស.អ.ប[20]។

៦. នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានចេញ *ដីកាសម្រេចលើសំណើជាបន្ទាន់របស់យឹម ទិត្យ សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី*[21] ដោយបដិសេធសំណើនេះ ហើយមិនឲ្យប៉ះពាល់ដល់សំណើបន្ទាន់ ព្រមទាំងបានបង្ហាញថា ការដាក់សារណាបន្ថែមទៀតទាក់ទងនឹងដីកាសម្រេចបឋម នឹងនៅតែពិចារណា[22]។ ស.ច.ស.អន្តរជាតិ កត់សម្គាល់ថា នៅ

---

[16]សំណុំរឿង ០០៤ ឯកសារ D186/1 *ដីកាសម្រេចទាក់ទងនឹងសំណើជាបន្ទាន់របស់យឹម ទិត្យ សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ* [ដីកាសម្រេចបឋម] ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤។

[17]ដីកាសម្រេចបឋម កថាខណ្ឌ ៧។ សំណុំរឿង ០០៤ ឯកសារ D109 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ[វិធាន ២១(១)(ឃ)]* ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១។ សំណុំរឿង ០០៤ ឯកសារ D111 *លិខិតជូនទៅអង្គភាពគាំពារការពារក្តីស្តីពីការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ[វិធាន ២១(១)(ឃ)]* ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២។

[18]ដីកាសម្រេចបឋម ទំព័រ ៤។

[19]សំណុំរឿង ០០៤ ឯកសារ D192 *សំណើជាបន្ទាន់របស់យឹម ទិត្យ សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។

[20]សំណុំរឿង ០០៤ ឯកសារ D192 *សំណើជាបន្ទាន់របស់យឹម ទិត្យ សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ៣-៤ និងទំព័រ ១ និង ៣។

[21]សំណុំរឿង ០០៤ ឯកសារ D192/1 *ដីកាសម្រេចលើសំណើជាបន្ទាន់របស់យឹម ទិត្យ សុំដំណោះស្រាយ ដោយ ផ្អែកលើព័ត៌មានថ្មី* ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។

[22]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១២ និង ១៤។

ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ជនសង្ស័យ បានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះទៅអង្គបុរេជំនុំជម្រះ(“អ.ប.ជ”)ប៉ុន្តែ រហូតមកដល់ថ្ងៃនេះ មិនទាន់មានចេញសាលដីកាឡើយ[23]។

៧. នៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីជនសង្ស័យ បានដាក់សារណាស្ដីពីការពិចារណាសាជាថ្មី[24] ដោយអះអាងថា គ្មានមូលដ្ឋានសមស្របសម្រាប់ការពិចារណាសាជាថ្មីទៅលើការជូនដំណឹងឡើយ ទាក់ទងនឹងសំណើសុំផ្ដល់ជូន អ.ប.ជ នូវពាក្យសុំមោឃភាពផ្នែកខ្លះចំពោះកិច្ចស៊ើបសួរប្រឆាំងនឹងជនសង្ស័យ[25]។

## សារណា

<u>ការចូលពិនិត្យមើលសំណុំរឿង និងការចូលរួមកិច្ចស៊ើបសួរ</u>

៨. នៅក្នុងសំណើបន្ទាន់ និងសារណាស្ដីពីការពិចារណាឡើងវិញ មេធាវីជនសង្ស័យ បានស្នើ ស.ច.ស បង្គាប់ឱ្យការិយាល័យរដ្ឋបាល អនុញ្ញាតឱ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿងភ្លាមៗ[26]។ មេធាវីជនសង្ស័យ បញ្ជាក់ថា ជនសង្ស័យ ត្រូវបានអនុញ្ញាត*តាមផ្លូវច្បាប់*រួចហើយឱ្យចូលពិនិត្យមើលសំណុំរឿង ប៉ុន្តែ រហូតមកដល់ពេលនេះ ជាក់ស្ដែង មិនមានការការអនុញ្ញាតបែបនេះឡើយ[27] ទោះបីជាថា រហូតមកដល់ពេលនេះ ដីកាសម្រេចរបស់ ស.ច.ស.អ.ប “*មិនទាន់ត្រូវបានយកទៅពិចារណាសាជាថ្មី រំលាយចោល ឬទុកជាមោឃៈនៅឡើយទេ*”[28]។ មេធាវីជនសង្ស័យ សន្និដ្ឋានថា *ជាក់ស្ដែង* ស.ច.ស.អន្តរជាតិ បានបដិសេធដោយមិនត្រឹមត្រូវក្នុងការសម្រេចមិនឱ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿង ដោយរំលោភ

---

[23]សំណុំរឿង ០០៤ ឯកសារ D192/1/1/1 *បណ្ដឹងឧទ្ធរណ៍របស់យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើបន្ទាន់របស់គាត់សុំឱ្យមានដំណោះស្រាយផ្អែកលើព័ត៌មានថ្មី* ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ។

[24]សារណាស្ដីពីការពិចារណាសាជាថ្មី ទំព័រ ១ និងកថាខណ្ឌ ៩-១៧។

[25]*ដូចជើងទំព័រខាងលើ* ទំព័រ ១ និងកថាខណ្ឌ ៤៣-៤៨។

[26]សំណើបន្ទាន់ ទំព័រ ១ និង ១៥។ សារណាស្ដីពីការពិចារណាសាជាថ្មី ទំព័រ ១៥។

[27]សារណាស្ដីពីការពិចារណាសាជាថ្មី កថាខណ្ឌ ២០-២១។

[28]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២១។

បំពានដល់គោលការណ៍នៃយុត្តិធម៌ធម្មជាតិ និងភាពត្រឹមត្រូវតាមនីតិវិធី ដូច្នេះបណ្តាលឲ្យប៉ះពាល់ដល់ជនសង្ស័យ[29]។

៩. មេធាវីជនសង្ស័យ ក៏ពឹងផ្អែកសំណើបន្ទាន់លើមូលដ្ឋានមួយចំនួនបន្ថែមទៀត។

*ជនសង្ស័យ "រងការចោទប្រកាន់"*

១០. មេធាវីជនសង្ស័យ អះអាងថា ជនសង្ស័យ បច្ចុប្បន្ននេះ *"រងការចោទប្រកាន់"* ដូច្នេះ មានសិទ្ធិទទួលបានសិទ្ធិជា"ជនត្រូវចោទ"[30] តាមសន្ទានុក្រមនៃវិធានផ្ទៃក្នុង ដែលចែងថា *"ជនណាម្នាក់ដែលត្រូវចោទប្រកាន់ចំពោះរឿងក្តីណាមួយ ក្នុងចន្លោះពេលពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រហូតដល់មានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់"*។ ត្រង់ចំណុចនេះ មេធាវីជនសង្ស័យ អះអាងថា សន្ទានុក្រមនេះ មិនផ្តល់និយមន័យឲ្យកាត់ផ្តាច់ចេញពីគ្នារវាង"ជនសង្ស័យ" និង "ជនត្រូវចោទ"ឡើយ[31]។

១១. ដោយកត់សម្គាល់ថា វិធានផ្ទៃក្នុង គួរតែបកស្រាយតាមមាត្រា ៣១(១)នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ដែលចែងថា សន្ធិសញ្ញាត្រូវបកស្រាយដោយសុចរិត និង "អនុលោមតាមអត្ថន័យធម្មតាដែលបានកំណត់ចំពោះពាក្យពេចន៍របស់សន្ធិសញ្ញា ទៅតាមបរិបទនៃពាក្យពេចន៍ទាំងនោះ និងទៅតាមកម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញានោះ" មេធាវីជនសង្ស័យ ដកស្រង់វចនានុក្រម Black's Law Dictionary ហើយអះអាងថា ដោយសារថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ បណ្តាលឲ្យមានកិច្ចស៊ើបសួរ នោះបុគ្គលណាម្នាក់ដែលមានឈ្មោះនៅក្នុងដីកានេះ គឺ *"រងការចោទប្រកាន់"*ភ្លាមៗនៅពេលដែលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[32]។

១២. មេធាវីជនសង្ស័យ អះអាងថា និយមន័យនេះអំពីជនត្រូវចោទ គឺស្របទៅនឹង *"ការបកស្រាយដែល ស.ច.ស បានអនុវត្តតាមក្នុងសំណុំរឿង ០០២"* ជាជំហរដែលមានធរមាននៅក្នុងច្បាប់

---

[29] *ដូចជើងទំព័រខាងលើ*។

[30] សំណើបន្ទាន់ កថាខណ្ឌ ១៨-២៤។ សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ២២-២៧។

[31] សំណើបន្ទាន់ កថាខណ្ឌ ១៨-១៩។ សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ២២-២៣។

[32] សំណើបន្ទាន់ កថាខណ្ឌ ២០។ សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ២៤។

បារាំង មុនពេលមានកំណែទម្រង់តុលាការដែលបានអនុវត្តនៅឆ្នាំ ១៩៨៣[33] ហើយជានិយមន័យដែលបានប្រើប្រាស់ដោយ ស.ច.ស.អ.ប[34] នៅពេលដែលគាត់ជូនដំណឹង ជនសង្ស័យថា ជនសង្ស័យ ជាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយគួរ "ទទួលបានសិទ្ធិទាំងឡាយដូចគ្នានឹងជនត្រូវចោទ..."[35]។ មេធាវីជនសង្ស័យ សន្និដ្ឋានថា ដោយសារថា អស់រយៈពេលជាង បួនឆ្នាំហើយ គ្មានដីកាសម្រេចណាមួយរបស់ ស.ច.ស ត្រូវបានធ្វើឡើងថាតើត្រូវឲ្យបង្ហាញខ្លួនលើកដំបូង ឬក៏លើកលែងការចោទប្រកាន់នោះ ទើបជនសង្ស័យ គួរតែទទួលបានសិទ្ធិជាជនត្រូវចោទ[36]។ មេធាវីជនសង្ស័យ អះអាងថែមទៀតថា អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា វិមតិសង្ស័យណាមួយគួរតែដោះស្រាយជាប្រយោជន៍ដល់ជនសង្ស័យ[37]។

*ការពារសិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌*

១៣. មេធាវីជនសង្ស័យ អះអាងថា ចាំបាច់ត្រូវចូលពិនិត្យមើលសំណុំរឿង ដើម្បីការពារសិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាពិសេស ដើម្បី"*ធានានូវសច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី ធានានូវសមភាពនៃមធ្យោបាយតទល់ក្តី និងធានានូវពេលវេលា និងធនធានសម្ភារៈគ្រប់គ្រាន់ក្នុងការត្រៀមរៀបចំការពារក្តីរបស់គាត់*"[38]។ ដោយពឹងផ្អែកលើយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប("ECtHR")ដែលជ្រើសរើសយកបញ្ហាសារធាតុ ជាជាងបញ្ហាទម្រង់ផ្លូវការនៃទស្សនាទានអំពីការចោទប្រកាន់នោះ មេធាវីជនសង្ស័យ អះអាងថា ជនម្នាក់រងការចោទប្រកាន់ខាងព្រហ្មទណ្ឌនៅពេលដែលគាត់ "*បានដឹងជាផ្លូវពីកិច្ចស៊ើបសួរ ឬចាប់ផ្តើមទទួលរងផលប៉ះពាល់ពីការចោទប្រកាន់នេះរួចទៅហើយ*"[39]។

---

[33]សំណើបន្ទាន់ កថាខណ្ឌ ២១។ សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ២៥។

[34]សំណើបន្ទាន់ កថាខណ្ឌ ២២។ សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ២៦។

[35]សំណើបន្ទាន់ កថាខណ្ឌ ២៤។

[36]សំណើបន្ទាន់ កថាខណ្ឌ ២៣-២៤។ សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ២៧។

[37]សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ២៧។

[38]សំណើបន្ទាន់ ទំព័រ ១ និង កថាខណ្ឌ ២៥។

[39]សំណើបន្ទាន់ កថាខណ្ឌ ២៦-២៧។ សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ២៩-៣០។

១៤. មេធាវីជនសង្ស័យ អះអាងថែមទៀតថា ចាំបាច់ត្រូវចូលពិនិត្យមើលសំណុំរឿង ដើម្បីឲ្យជនសង្ស័យចូលរួមប្រកបដោយអត្ថន័យនៅក្នុងកិច្ចស៊ើបសួរ ពីព្រោះថា ភាគីទាំងអស់ គប្បីចូលរួមកិច្ចស៊ើបសួរ*"ចាប់តាំងពីឱកាសដំបូងបំផុតតាមដែលអាចធ្វើទៅបាន"*[40]។ មេធាវីជនសង្ស័យ ក៏បង្ហាញសេចក្តីព្រួយបារម្ភទាក់ទងនឹងសេចក្តីរាយការណ៍មួយរបស់ប្រព័ន្ធផ្សព្វផ្សាយដែលថា ស.ច.ស.អន្តរជាតិ មានបំណងបិទកិច្ចស៊ើបសួរនៅចុងឆ្នាំ ២០១៤[41]។

១៥. បន្ថែមពីលើនេះទៀត មេធាវីជនសង្ស័យ អះអាងថា ជនសង្ស័យ *"ស្ថិតក្នុងស្ថានភាពដូចគ្នានឹងជនត្រូវចោទទាំងឡាយក្នុងសំណុំរឿង ០០២"* ដូច្នេះ ដើម្បីធានាឲ្យមានសច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធានផ្ទៃក្នុង ២១(១)(ខ) ជនសង្ស័យ គប្បីទទួលបានសិទ្ធិដូចគ្នាដែលផ្តល់ទៅឲ្យជនត្រូវចោទទាំងឡាយនៅក្នុងសំណុំរឿង ០០២ ដែលត្រូវបានចោទប្រកាន់ ត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង និងឱកាសចូលរួមកិច្ចស៊ើបសួរ បន្ទាប់ពីដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រយៈពេលប្រហែលជា បួន ខែ[42]។

១៦. បន្ថែមពីលើនេះទៀត ដោយរំឭកថា សហព្រះរាជអាជ្ញា អាចចូលពិនិត្យមើលសំណុំរឿងចាប់តាំងពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ហើយដើមបណ្តឹងរដ្ឋប្បវេណី អាចចូលពិនិត្យមើលសំណុំរឿង ចាប់តាំងពីថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១១មក មេធាវីជនសង្ស័យ អះអាងថា *"ភាពខុសគ្នានៃពេលវេលា"*ចូលរួមក្នុងកិច្ចស៊ើបសួរ និងការចូលពិនិត្យមើលសំណុំរឿងរវាងភាគីនានា "បង្កើតបានជាអតុល្យភាព ទោះបីជាជាក់ស្តែង ឬដោយប្រយោលក្តី រវាងលទ្ធភាពរបស់ភាគីនានាក្នុងការបញ្ជាក់អះអាងពីរឿងក្តីរបស់ខ្លួន" ដែលបញ្ហានេះ "តាមពេលវេលាដែលនឹងកន្លងទៅ... នឹងមិននាំឲ្យមានលទ្ធភាពជួសជុល ឬដោះស្រាយបានក៏ដោយ ក៏វានឹងនាំឲ្យមានការលំបាកកាន់តែខ្លាំងក្នុងការយកនីតិវិធីការពារមកជួសជុល ឬដោះស្រាផងដែរ"[43]។

១៧. ចុងក្រោយបំផុត ដោយពឹងផ្អែកលើយុត្តិសាស្ត្ររបស់តុលាការ ECtHR មេធាវីជនសង្ស័យ បញ្ជាក់អំពីសារៈសំខាន់នៃដំណាក់កាលស៊ើបសួរនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលធានាការគោរពសិទ្ធិ ពេលវេលា និងធនធានសម្ភារៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារក្តី។

---

[40] សំណើបន្ទាន់ កថាខណ្ឌ ២៨។ សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ៣១។

[41] សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ៣២-៣៣។

[42] សំណើបន្ទាន់ កថាខណ្ឌ ២៩-៣០។ សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ៣៤-៣៥។

[43] សំណើបន្ទាន់ កថាខណ្ឌ ៣១-៣៣។ សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ៣៦-៣៨។

មេធាវីជនសង្ស័យ សន្និដ្ឋានថា ប្រសិនបើជនសង្ស័យ ត្រូវបានចោទបញ្ជូនទៅជំនុំជម្រះ ដោយមិនអនុញ្ញាតឲ្យមានពេលវេលាគ្រប់គ្រាន់ដើម្បីត្រួតពិនិត្យសំណុំរឿង និងចូលរួមកិច្ចស៊ើបសួរទេ នោះ“ *បញ្ហានេះនឹងនាំឲ្យកិច្ចស៊ើបសួរទាំងមូលមានវិការៈ និងត្រូវចាត់ទុកជាមោឃៈ*”[44] ។

<u>ការពិចារណាសាជាថ្មីទៅលើការជូនដំណឹង</u>

១៨. មេធាវីជនសង្ស័យ អះអាងថា ស.ច.ស.អន្តរជាតិ មិនមានមូលដ្ឋានស្របច្បាប់ដើម្បីពិចារណាសាជាថ្មីទៅលើការជូនដំណឹង ឡើយ[45]។ មេធាវីជនសង្ស័យ អះអាងថា ពុំមានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យ ស.ច.ស.អន្តរជាតិ ពិចារណាឡើងវិញទៅលើសេចក្តីសម្រេចមុនៗឡើយ[46]។ មេធាវីជនសង្ស័យ អះអាងថែមទៀតថា ប្រសិនបើ ស.ច.ស.អន្តរជាតិ មានឆន្ទានុសិទ្ធិពិចារណាឡើងវិញ នោះក៏មិនបានបំពេញតាមបទដ្ឋានដែលតម្រូវឲ្យមានការពិចារណាឡើងវិញដែរ[47]។ មេធាវីជនសង្ស័យ អះអាងថា ពុំមានការផ្លាស់ប្តូរកាលៈទេសៈទេចាប់តាំងពី ស.ច.ស.អ.ប បានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង[48] ហើយក៏មិនបណ្តាលឲ្យមានភាពអយុត្តិធម៌ដោយសារសេចក្តីសម្រេចរបស់ ស.ច.ស.អ.ប ដែរ[49]។ មេធាវីជនសង្ស័យ អះអាងទៀតថា ដោយសារថា ការអនុញ្ញាតរបស់ ស.ច.ស.អ.ប ឲ្យចូលពិនិត្យមើលសំណុំរឿង បានការពារសិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយមិនធ្វើឲ្យប៉ះពាល់ដល់ភាគីណាផ្សេងទៀតនៅក្នុងកិច្ចដំណើរការនីតិវិធី នោះគឺមិនអាចមានកំហុសណាមួយជាក់លាក់នៅក្នុងសំអាងហេតុរបស់ ស.ច.ស.អ.ប ឡើយ[50]។

---

[44]សំណើបន្ទាន់ កថាខណ្ឌ ៣៤-៣៦។ សារណាស្តីពីការពិចារណាសាជាថ្មី កថាខណ្ឌ ៣៩-៤២។

[45]សារណាស្តីពីការពិចារណាសាជាថ្មី ទំព័រ ១។

[46]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៩-១០។

[47]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១១-១៧។

[48]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៣។

[49]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៤។

[50]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៦។

<u>ការផ្ដើមោយភាពកិច្ចស៊ើបសួរ អនុលោមតាមវិធានផ្ទៃក្នុង ៧៦</u>

១៩. មេធាវីជនសង្ស័យ ក៏ស្នើ ស.ច.ស បញ្ជូនជូន អ.ប.ជ នូវពាក្យសុំមោឃភាពកិច្ចស៊ើបសួរ ទាក់ទងនឹងជនសង្ស័យ ចាប់តាំងពីថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៤ នៅពេលដែលការចូលពិនិត្យមើលសំណុំរឿង ត្រូវបានស្នើឡើងជាលើកដំបូង រហូតទាល់តែសំណើសុំចូលពិនិត្យមើលសំណុំរឿងត្រូវបានអនុញ្ញាត[51] ពីព្រោះថា ស.ច.ស.អ.ប បានអនុញ្ញាត*តាមផ្លូវច្បាប់*ឲ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿង ប៉ុន្តែ *តាមជាក់ស្ដែង* ការអនុញ្ញាតនេះត្រូវបានបដិសេធដោយ ស.ច.ស.អន្តរជាតិ ចាប់តាំងពីមេធាវីជនសង្ស័យ បានស្នើជាលើកដំបូង នៅថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៤[52]។ នេះគឺជាវិការៈផ្នែកនីតិវិធី ដែលបានរំលោភសិទ្ធិរបស់ជនសង្ស័យ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[53]។

## ច្បាប់ជាធរមាន

<u>វិធានផ្ទៃក្នុង ២១(១) របស់ អ.វ.ត.ក ចែងពីផ្នែកពាក់ព័ន្ធថា៖</u>

"ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព។

[...]

ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។

[...]

ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅ

---

[51] សារណាស្ដីពីការពិចារណាសាជាថ្មី កថាខណ្ឌ ៤៣ និង ៤៧-៤៨។

[52] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៤-៤៥។

[53] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៦-៤៨។

ក្នុងគ្រប់ដំណាក់កាល ទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប"។

<u>វិធានផ្ទៃក្នុង ៥៥ របស់ អ.វ.ត.ក ចែងពីផ្នែកពាក់ព័ន្ធថា៖</u>

"[...]

សហចៅក្រមស៊ើបអង្កេត មានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយណា ដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរផងដែរ ចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថាបុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ។ ក្នុងករណីចុងក្រោយនេះ សហ-ចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់សហព្រះរាជអាជ្ញាមុនពេលដាក់បុគ្គលនោះឲ្យស្ថិតនៅក្រោមការពិនិត្យ។

[...]

ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវរក្សាទុកសំណុំរឿង រួមទាំងកំណត់ហេតុ និងរបាយការណ៍នៃការស៊ើបសួរ។ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ មានសិទ្ធិគ្រប់ពេលវេលាក្នុងការពិនិត្យ និងថតចម្លងសំណុំរឿង ក្រោមការឃ្លាំមើលរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើប- អង្កេត ក្នុងពេលម៉ោងធ្វើការ និងគោរពទៅតាមបទបញ្ជារបស់អង្គជំនុំជម្រះវិសាមញ្ញ។

[...]

នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមាន ប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកា បដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឲ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី។ ដីកាបដិសេធនេះបើកផ្លូវប្តឹងឧទ្ធរណ៍"។

<u>វិធានផ្ទៃក្នុង ៥៧ របស់ អ.វ.ត.ក ចែងពីផ្នែកពាក់ព័ន្ធថា៖</u>

"នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន ចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និងប្រាប់ជននោះអំពីបទចោទប្រកាន់ និងអំពីសិទ្ធិមាន មេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។ ជនត្រូវចោទមានសិទ្ធិពិគ្រោះជាមួយមេធាវីមុនពេលដែលខ្លួនត្រូវបានសួរចម្លើយ និងមានមេធាវីអមជាមួយនៅក្នុងពេលសួរចម្លើយ។ ប្រសិនបើជនត្រូវចោទយល់ ព្រមឆ្លើយ នោះសហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការសួរចម្លើយនោះភ្លាម។ កំណត់ហេតុសួរចម្លើយត្រូវដាក់ចូលក្នុងសំណុំរឿង"។

<u>វិធានផ្ទៃក្នុង ៧៦(២) របស់ អ.វ.ត.ក ចែងពីផ្នែកពាក់ព័ន្ធថា៖</u>

"ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថា មានផ្នែកណាមួយត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត ប្ដឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឲ្យធ្វើមោឃភាព។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដែលអាចជាការទទួលយក ឬ បដិសេធសំណើសុំភ្លាមៗតាមតែអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ។ ដីកាបែបនេះ គឺជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ ដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ"។

## **ពិភាក្សា**

### **សុពលភាពនៃការជូនដំណឹង**

២០. មានមូលដ្ឋានរឹងមាំល្អនៅកម្រិតអន្តរជាតិ ដែលចៅក្រម មានអំណាចឆន្ទានុសិទ្ធិមានស្រាប់ ដើម្បីពិចារណាឡើងវិញទៅលើសេចក្ដីសម្រេចមុនៗ។ ដោយពឹងផ្អែកលើសាលាក្ដីអន្តរជាតិពិសេស ៗ អ.ប.ជ បានបញ្ជាក់ថា សេចក្ដីសម្រេចណាមួយអាចយកមកពិចារណាឡើងវិញ

ក្នុងករណីដែលមានការប្រែប្រួលកាលៈទេសៈ[54] ដែលជាកំហុសមួយច្បាស់លាស់នៅក្នុងសំអាងហេតុ ឬក្នុងករណីដែលសេចក្តីសម្រេចនោះបានបណ្តាលឲ្យមានភាពអយុត្តិធម៌[55]។

២១. សហចៅក្រមស៊ើបអង្កេតនៅ អ.វ.ត.ក បានប្រើប្រាស់អំណាចនេះនៅក្នុងសេចក្តីសម្រេចមុនៗ[56]។ ជាពិសេស ស.ច.ស.អន្តរជាតិ ធ្លាប់បានពិចារណាឡើងវិញទៅលើសេចក្តីសម្រេចមួយរបស់ ស.ច.ស.អ.ប ដែលអនុញ្ញាតឲ្យជនសង្ស័យម្នាក់ទៀតនៅក្នុងសំណុំរឿង ០០៤ ចូលពិនិត្យមើលសំណុំរឿង (“ដីកាសម្រេចពិចារណាឡើងវិញ”)[57]។ នៅក្នុងដីកាសម្រេចពិចារណាឡើងវិញ ស.ច.ស.អន្តរជាតិ យល់ឃើញថា “ការចូលពិនិត្យមើលសំណុំរឿង ត្រូវបានអនុញ្ញាតដោយរំលោភលើវិធានផ្ទៃក្នុង ដោយគ្មាននីតិវិធីដំបូងដែលត្រូវចោទជនសង្ស័យជាផ្លូវ

---

[54]ការប្រែប្រួលកាលៈទេសអាចរួមមាន អង្គហេតុ ឬទឡ្ហីករណ៍ថ្មី។ សូមមើលសំណុំរឿង ០០២ ឯកសារ C22/I/68*សេចក្តីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង* ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ២៥។

[55]សំណុំរឿង ០០២ ឯកសារ C22/I/68*សេចក្តីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង* ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ២៥។ សំណុំរឿង ០០២ ឯកសារ D164/4/9 *សេចក្តីសម្រេចសំណើសុំឲ្យពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេច ទាក់ទងនឹងសំណើសុំឲ្យមានសវនាការដើម្បីពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្រមខណ្ឌនៃសំណុំរឿង អ.ប.ជ ២៤ និង ២៥* ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ១២។ សំណុំរឿង ០០១ ឯកសារ D99/3/41 *សេចក្តីសម្រេចលើពាក្យសុំពិចារណាឡើងវិញចំពោះសេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំនៅក្នុងសំណុំរឿង “ឌុច”* ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៦។ សំណុំរឿង០០២ ឯកសារ D364/1/6 *សាលដីកាសម្រេចអំពីការពិចារណាសាជាថ្មីឡើងវិញអំពីការទទួល យកពាក្យសុំតាំង ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ៦។ *សូមមើលផងដែរ* សាលាក្តីព្រហ្មទណ្ឌ អន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Jadranko Prlić*និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-AR73.16 *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់របស់* Jadranko Prlić *ប្រឆាំងនឹងសេចក្តីសម្រេចលើញត្តិរបស់ក្រុមការពារក្តី* Prlić*សុំឲ្យពិចារណាឡើងវិញទៅលើសេចក្តីសម្រេចទទួលយកភស្តុតាងឯកសារ* ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៦។

[56]សំណុំរឿង ០០៣&០០៤ ឯកសារ D4/2/1 *ដីកាសម្រេចស្តីអំពីសំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១* ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ៣។ សំណុំរឿង ០០៤ ឯកសារ D121/4 *សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី [កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១១ ចំណងជើងរង គ។

[57]សំណុំរឿង ០០៤ ឯកសារ D121/4 *សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី [កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣។

ការ ដោយអនុលោមតាមវិធានផ្ទៃក្នុង ៥៧។ ស.ច.ស.អ.ប ក៏មិនបានសម្រេចថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ប្រឆាំងនឹងជនសង្ស័យដែរ"[58]។ ការពិចារណាទាំងនេះ ក៏អនុវត្តផងដែរចំពោះករណីបច្ចុប្បន្ននេះ។

២២. តាមរយៈការអនុញ្ញាតឲ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿង ស.ច.ស.អ.ប បានផ្តល់ឲ្យជនសង្ស័យនូវសិទ្ធិដែលជនសង្ស័យពុំមានសិទ្ធិទទួលបានអនុលោមតាមវិធានផ្ទៃក្នុង។ ស.ច.ស.អ.ប បានធ្វើដូច្នេះដោយប្រកាន់យកការអនុវត្តស្រដៀងគ្នា ដោយមិនបានផ្តល់សំអាងហេតុដើម្បីគាំទ្រសេចក្តីសម្រេចរបស់គាត់ឡើយ[59]។ ដោយមិនបានផ្តល់ការពន្យល់ណាមួយគាត់ក៏បានផ្តល់ឲ្យជនសង្ស័យ នូវសិទ្ធិតែមួយចំនួនប៉ុណ្ណោះក្នុងចំណោមសិទ្ធិរបស់ជនត្រូវចោទដោយដកសិទ្ធិចូលរួមកិច្ចស៊ើបសួរ[60]។

២៣. បន្ថែមពីលើនេះទៀត ស.ច.ស.អន្តរជាតិ មិនជឿថា នៅពេលដែល ស.ច.ស.អ.ប បានចេញការជូនដំណឹងនោះ មាន "តម្រុយច្បាស់លាស់ និងស៊ីសង្វាក់"ដែលបញ្ជាក់ថា ជនសង្ស័យ អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលបានចោទប្រឆាំងនឹងគាត់ឡើយ។ នាពេលបច្ចុប្បន្ននេះ ស.ច.ស.អន្តរជាតិ មិនទាន់កំណត់ថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញហើយឬនៅទេ។

២៤. ចុងក្រោយបំផុត ស.ច.ស.អន្តរជាតិ កត់សម្គាល់ថា អនុលោមតាមវិធានផ្ទៃក្នុង ៥៦ កិច្ចស៊ើបសួរ គឺជាការសម្ងាត់។ វិធានផ្ទៃក្នុង ផ្តល់ឲ្យតែភាគីនានានៅក្នុងកិច្ចដំណើរការនីតិវិធី នូវសិទ្ធិចូលពិនិត្យមើលកំណត់ហេតុនៃកិច្ចស៊ើបសួរ។ ជនសង្ស័យណាម្នាក់ មិនមែនជា ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ[61]។ នៅដំណាក់កាលនេះ ការផ្តល់ការអនុញ្ញាតឲ្យចូល ពិនិត្យមើលសំណុំរឿងទៅឲ្យជនសង្ស័យណាម្នាក់ដែលអាច ឬមិនអាចត្រូវបានចោទប្រកាន់ គឺមិនមែនជាប្រយោជន៍យុត្តិធម៌ ហើយអាចបង្កគ្រោះថ្នាក់ដល់ភាពសម្ងាត់នៃកិច្ចស៊ើបសួរ។

---

[58] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៧។

[59] សំណុំរឿង ០០៤ ឯកសារ D109 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ[វិធាន ២១(១)(ឃ)]* ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៤។

[60] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣-៥។

[61] សូមមើលវិធានផ្ទៃក្នុង ៥៥ និង ៨៦។ សូមមើលផងដែរ សំណុំរឿង ០០៤ ឯកសារ D121/4 *សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី [កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៦-៣៩។

២៥. ដោយផ្អែកលើមូលដ្ឋាននៃការពិចារណាទាំងនេះ ស.ច.ស.អន្តរជាតិ យល់ឃើញថា តាមរយៈការអនុញ្ញាតឱ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿង ស.ច.ស.អ.ប បានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ហើយបានប្រព្រឹត្តកំហុសមួយនៅក្នុងសំអាងហេតុ[62]។

**ជនសង្ស័យ មិនមែនជា "ជនត្រូវចោទ"**

២៦. វិធានផ្ទៃក្នុង បែងចែកយ៉ាងច្បាស់រវាងជនសង្ស័យ និងជនត្រូវចោទ ហើយផ្ដល់ជូនជនត្រូវចោទ នូវសិទ្ធិកាន់តែទូលំទូលាយ[63]។ ឋានៈជា "ជនត្រូវចោទ" និងសិទ្ធិនៅជាប់ជាមួយនឹងឋានៈនេះ ត្រូវបានជនសង្ស័យណាម្នាក់ទទួលបាន បន្ទាប់ពី សហចៅក្រមស៊ើបអង្កេត សម្រេចដោយឆន្ទានុសិទ្ធិចោទប្រកាន់ជាផ្លូវការប្រឆាំងនឹងជនសង្ស័យនោះតែប៉ុណ្ណោះ[64]។ ចំណុចនេះអនុវត្តចំពោះជនសង្ស័យដែលមានឈ្មោះ និងជនសង្ស័យដែលមិនមានឈ្មោះ[65]។ ពេលវេលា

---

[62]សំណុំរឿង ០០៤ ឯកសារ D121/4 *សេចក្ដីសម្រេចលើសំណើរបស់ក្រុមការពារក្ដី [កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៩។

[63]សំណុំរឿង ០០៤ ឯកសារ D121/4 *សេចក្ដីសម្រេចលើសំណើរបស់ក្រុមការពារក្ដី [កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៦។

[64]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣៣-៤៩ និង ៦២។ សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២ បានបញ្ជាក់ថា ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ[ការចោទ] "*មិនមែនជាទម្រង់ការនីតិវិធីធម្មតាទេ ប៉ុន្តែជាសេចក្ដីសម្រេចតុលាការមួយរបស់សហចៅក្រមស៊ើបសួរនៅពេលណាដែលខ្លួនយល់ឃើញថា មានភស្តុតាងជាក់លាក់ និងស៊ីសង្វាក់បញ្ជាក់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌប្រឆាំងនឹងជនណាមួយ*" *សូមមើល* សំណុំរឿង ០០២ ឯកសារ D 298/2 *ដីកាសម្រេចបដិសេធការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យបន្ថែម* ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០ កថាខណ្ឌ ១៣។

[65]សំណុំរឿង ០០២ ឯកសារ D 298/2 *ដីកាសម្រេចបដិសេធការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យបន្ថែម* ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០ កថាខណ្ឌ ១៣។ សំណុំរឿង ០០២ ឯកសារ D198/1 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ១០ "*ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ អាចធ្វើទៅបានចំពោះតែបុគ្គលដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋកម្មដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ ទោះបីជាបុគ្គលនោះមាន ឬមិនមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ*"។ តុលាការជាន់ខ្ពស់បារាំង ដែលសេចក្ដីសម្រេចរបស់តុលាការនេះមិនជាប់កាតព្វកិច្ចនៅ អ.វ.ត.ក ប៉ុន្តែអាចជួយផ្ដល់ជាការណែនាំអំពីបញ្ហាការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ បានបញ្ជាក់ថា សេចក្ដីសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ត្រូវតែប្រកាសមោឃភាពនៅពេលដែលសេចក្ដីសម្រេចនេះបានធ្វើឡើងដោយគ្មានភស្តុតាងរឹងមាំ និងច្បាស់លាស់ដែលបញ្ជាក់ថា ជនសង្ស័យអាចបានចូលរួមឧក្រិដ្ឋកម្មដែលចោទប្រឆាំងនឹងគាត់ *សូមមើល* 1er oct. 2003, N. 03-82.909: JurisData n 2003 020541; Bull. Crim. 2003, n. 177។

ដែលកន្លងទៅចាប់តាំងពីពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ មិនផ្តល់ជាយុត្តិកម្មឲ្យដើរខុសពីនីតិវិធីដែលកំណត់ដោយវិធានផ្ទៃក្នុង ឡើយ។ ស្រដៀងគ្នានេះដែរ វិធានដែលចែងពីការចូលពិនិត្យមើលសំណុំរឿង មិនអាចត្រូវរំលងដោយសារយកនិយមន័យច្បាប់ជាទូទៅស្តីពីទស្សនាទានច្បាប់មកអនុវត្តនៅក្នុងប្រព័ន្ធនីតិវិធីកម្ពុជាដែលជំរុញតាមលំនាំបារាំងឡើយ។

២៧. នៅក្នុងការវាយតម្លៃថាតើនៅពេលណាជនណាម្នាក់រងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ដោយពឹងផ្អែកលើយុត្តិសាស្ត្ររបស់តុលាការ ECtHR សេចក្តីសម្រេចមុនៗនៅក្នុងសំណុំរឿង ០០៤ ក៏បានពិចារណាទៅលើសំណួរថាតើជននោះ ត្រូវបាន“ប៉ះពាល់យ៉ាងធ្ងន់ធ្ងរ”ដោយសារអត្ថិភាពនៃការចោទប្រកាន់ព្រហ្មទណ្ឌប្រឆាំងនឹងគាត់ ឬអត់[66]។ នៅក្នុងករណីបច្ចុប្បន្ននេះ ស.ច.ស.អន្តរជាតិ មិនយល់ឃើញថា ការជូនដំណឹងអំពីការចោទប្រកាន់ទៅជនសង្ស័យ បានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជនសង្ស័យ ដែលតម្រូវឲ្យដើរខុសពីវិធានផ្ទៃក្នុង និងតម្រូវឲ្យផ្តល់សិទ្ធិដែលរក្សាទុកសម្រាប់ជនត្រូវចោទឡើយ[67]។

២៨. ដោយគិតទៅលើការពិចារណាខាងលើ ជនសង្ស័យ បច្ចុប្បន្ននេះ មិនមែនជាជនត្រូវចោទនៅក្នុងសំណុំរឿង ០០៤ ឡើយ។

## ការចូលរួមកិច្ចស៊ើបសួរ

២៩. ការអះអាងរបស់មេធាវីជនសង្ស័យដែលថា ចាំបាច់ត្រូវពិនិត្យមើលសំណុំរឿងដើម្បីចូលរួមកិច្ចស៊ើបសួរប្រកបដោយអត្ថន័យ គឺមិនបានពិចារណាថា អនុលោមតាមវិធានផ្ទៃក្នុង ៥៥(១០) មានតែជនត្រូវចោទប៉ុណ្ណោះ មិនមែនជនសង្ស័យទេដែលអាចចូលរួមកិច្ចស៊ើបសួរ។ ប្រសិនបើជនសង្ស័យត្រូវបានចោទ គាត់នឹងអាចអនុវត្តយ៉ាងពេញលេញនូវសិទ្ធិទាំងអស់របស់ជនត្រូវចោទ អនុលោមតាមវិធានផ្ទៃក្នុង។ មិនគិតពីអ្វីដែលសារព័ត៌មានអាចរាយការណ៍នោះឡើយ

---

[66] សំណុំរឿង ០០៤ ឯកសារ D121/4 *សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី [កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៥០។ សំណុំរឿង ០០៤ ឯកសារ D4/1 *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និងលេខ ០០៤* ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៣-៨ និង ១២-១៣។

[67] សំណុំរឿង ០០៤ ឯកសារ D121/4 *សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី [កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៥៥ និង៥៨។

ស.ច.ស.អន្តរជាតិ នឹងធានាថា ភាគីទាំងអស់ មានពេលវេលាគ្រប់គ្រាន់ដើម្បីឲ្យខ្លួនដឹងអំពីភស្តុតាង និងអនុវត្តសិទ្ធិប្រកបដោយប្រសិទ្ធភាពមុនពេលបិទកិច្ចស៊ើបសួរ[68]។

## ការប្រព្រឹត្តដោយស្មើភាពគ្នាជាមួយនឹងជនត្រូវចោទនៅក្នុងសំណុំរឿង ០០២

៣០. ថាតើជនសង្ស័យ នឹងត្រូវចោទ ឬក៏មិនត្រូវចោទ និងពេលវេលានៃការចោទប្រកាន់ណាមួយនោះ នឹងអាស្រ័យលើថាតើមានតម្រុយច្បាស់ និងស៊ីសង្វាក់ដែលបញ្ជាក់ថា គាត់អាចទទួលខុសត្រូវចំពោះការចោទប្រកាន់ប្រឆាំងនឹងគាត់ ឬអត់។ អង្គហេតុដែលថា ស.ច.ស នៅក្នុងសំណុំរឿង០០២ បានសម្រេសចោទជនសង្ស័យពីរម្នាក់ក្នុងចំណោមជនសង្ស័យទាំងអស់បន្ទាប់ពីដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រយៈពេលប្រហែលជាបួនខែ គឺមិនមែនបង្ហាញថា ហើយក៏មិនអាចបង្ហាញថា ពេលវេលាដូចគ្នាត្រូវតែអនុវត្តនៅក្នុងសំណុំរឿង០០៤ដែរ។ ភាពខុសគ្នានៃពេលវេលាក្នុងការចោទនៅក្នុងសំណុំរឿង ០០២ និងសំណុំរឿង ០០៤ ត្រូវបានផ្តល់យុត្តិកម្មតាមរយៈការវាយតម្លៃទៅលើភស្តុតាង ដែលប្រមូលបាននាពេលកន្លងមកនៅក្នុងសំណុំរឿង ០០៤ ហើយក៏មិនរំលោភសិទ្ធិជាសារវ័ន្តរបស់ជនសង្ស័យក្នុងការទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នា ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ២១(១)ដែរ។

៣១. ស.ច.ស.អន្តរជាតិ បញ្ជាក់ឡើងវិញថា ប្រសិនបើត្រូវចោទ ជនសង្ស័យ នឹងត្រូវផ្តល់ជូននូវពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីរបស់ខ្លួន។ សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ មិនតម្រូវថា ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ត្រូវផ្តល់ជូននូវពេលវេលាដូចគ្នានឹងសហព្រះរាជអាជ្ញា ឬភាគីផ្សេងទៀតឡើយ[69]។

---

[68] ស.ច.ស.អន្តរជាតិ នឹងមិនបញ្ចេញមតិយោបល់លើការប៉ាន់ស្មាននានានៅក្នុងអំឡុងពេលស៊ើបអង្កេតដែលបានផ្សព្វផ្សាយដោយសារព័ត៌មាន និងលើកយោងដោយមេធាវីជនសង្ស័យឡើយ។

[69] តុលាការICTR៖ *វ្នអាជ្ញាតទល់នឹង Augustin Ngirabatware* សំណុំរឿងលេខ ICTR-99-54-A *សេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍របស់ Augustin Ngirabatware ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធញត្តិនានាដែលស្នើសុំឲ្យកំណត់កាលបរិច្ឆេទសវនាការនៅថ្ងៃផ្សេងៗគ្នា* ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ២៨។ តុលាការ ECtHR: *Ferrari-Bravo តទល់នឹងអ៊ីតាលី* , ECtHR (1984) 37 DR 15 ទំព័រ ៤០។ សាលាក្តីពិសេសសម្រាប់លីបង់៖ *វ្នអាជ្ញាតទល់នឹង Salim Jamil Ayyash និងអ្នកផ្សេងទៀត* សំណុំរឿងលេខSTL-11-01/T/TC *សេចក្តីសម្រេចលើការរៀបចំសវនាការ និងសំអាងហេតុសម្រាប់សេចក្តីសម្រេចលើ Joinder* ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ១០៧-១១៦។

01024231



## សំណើសុំមោឃភាពកិច្ចស៊ើបសួរ

៣២. ស.ច.ស.អន្តរជាតិ កន្លងមកបានសម្រេចលើសិទ្ធិរបស់ជនសង្ស័យម្នាក់ក្នុងការស្នើសុំមោឃភាព[70]។ វិធានផ្ទៃក្នុង ៤៨ និង ៧៦ ដែលពាក់ព័ន្ធនឹងចំណុចនេះ គឺស្របគ្នាទាំងស្រុងជាមួយនឹងច្បាប់កម្ពុជា។ មានតែ ព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី តែ ប៉ុណ្ណោះដែលអាចដាក់សំណើសុំមោឃភាពកិច្ចស៊ើបសួរ អនុលោមតាមមាត្រា ២៥៣ នៃក្រមនីតិព្រហ្មទណ្ឌរបស់កម្ពុជា។ ជនសង្ស័យ ដោយមិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី មិនមានសិទ្ធិដាក់ពាក្យសុំមោឃភាពអនុលោមតាមវិធានផ្ទៃក្នុង ៧៦ ឡើយ។

## សេចក្តីសន្និដ្ឋាន

៣៣. ដោយផ្អែកលើមូលដ្ឋានខាងលើ ស.ច.ស.អន្តរជាតិ យល់ឃើញថាចាំបាច់ត្រូវពិចារណាឡើងវិញទៅលើការជូនដំណឹង និងលុបចោលផ្នែកដែលអនុញ្ញាតឲ្យជនសង្ស័យ ចូលពិនិត្យមើលសំណុំរឿង។ ជនសង្ស័យមិនទាន់ត្រូវបានចោទជាផ្លូវការ ហើយគាត់មិនត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារកិច្ចស៊ើបសួរ ដោយខុសពីវិធានផ្ទៃក្នុងឡើយ។ ដូច្នេះ សំណើរបស់គាត់សុំចូលពិនិត្យមើលសំណុំរឿង នៅដំណាក់កាលនេះ ត្រូវបានបដិសេធ។ ចុងក្រោយបង្អស់ សំណើសុំផ្តល់ជូន អ.ប.ជ នូវពាក្យសុំមោឃភាពកិច្ចស៊ើបសួរទាក់ទងនឹង ជនសង្ស័យចាប់តាំងពីថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៤ មិនអាចទទួលយកបាន ដោយសារខ្វះសិទ្ធិ។

៣៤. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

## តាមសំអាងហេតុខាងលើ ខ្ញុំ MARK B. HARMON ៖

៣៥. **ពិចារណាឡើងវិញទៅលើ**ការជូនដំណឹង និងលុបចោលការអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង។

៣៦. **បដិសេធ**សំណើដែលបានស្នើនៅក្នុងសំណើបន្ទាន់។

៣៧. **បដិសេធ**សំណើដែលបានស្នើនៅក្នុងសារណាស្តីពីការពិចារណាសាជាថ្មី។

[70] សំណុំរឿង ០០៤ ឯកសារ D185/1 *ដីកាសម្រេចលើញត្តិ[កោសលុប]ស្នើសុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង* ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ១៩-២២។

01024232



ភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤

**ចៅក្រម Mark B. Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**